# ជំពូកទី ២

# រចនាសម្ព័ន្ធទូទៅ របស់ទេសចរណ៍



សកម្មភាពទេសចរក្នុងប្រទេសកម្ពុជា

SOM Sovann, MCom.
Full-time lecturer
IIC University of Technology
Building No. 650, Road No. 2,
Sangkat Chak Angre Krom,
Khan Mean Chey, Phnom Penh,
CAMBODIA.
Tel : +855-23-425 148
Fax : +855-23-425 149
Mobile: +855-17-950 097
Email: s.sovann@iic.edu.kh
somsovannkh@yahoo.com
Website: www.iic.edu.kh
F: facebook.com/iic1999
T: twitter.com/iic1999
g+: gplus.to/iic1999

## ២-១-និយមន័យទេសចរណ៍

ពាក្យ **ទេសចរណ៍** (Tourism) កើតឡើងនៅក្នុងភាសាអង់គ្លេសនៅដើមសតវត្សទី១៩ ហើយឫសគល់នៃពាក្យនេះ ដូចបង្ហាញក្នុងជំពូកទី១ ខាងលើគឺ Tour មានន័យថា ជាការធ្វើដំណើរកម្សាន្ត។

និយមន័យទេសចរណ៍ ត្រូវបានធ្វើឡើងតាមរយៈចរិកលក្ខណៈសេដ្ឋកិច្ចរបស់វា ដូចខាងក្រោមៈ

- ជាលទ្ធផលនៃការធ្វើដំណើរទៅកាន់តំបន់ណាមួយផ្សេងពីកន្លែងរស់នៅអចិន្ត្រៃយ៍
- ស្នាក់នៅ និងស្ថិតនៅក្នុងតំបន់ដែលទៅដល់ លើសពី២៤ម៉ោង
- ធ្វើសកម្មភាពជាមួយគោលបំណងទេសចរណ៍ស្របច្បាប់ដែលអនុញ្ញាត
- វិលត្រឡប់ទៅកន្លែងរស់នៅដើមវិញក្រោយបញ្ចប់សកម្មភាព
- មិនធ្វើការងារដែលទទួលបាននូវប្រាក់កម្រៃផ្ទាល់ខ្លួន (ចាយនិងបន្សល់ទុកប្រាក់ក្នុងតំបន់)។

**រូបទី ២.១. ចរិតលក្ខណៈសេដ្ឋកិច្ចរបស់ទេសចរណ៍**




អង្គការសហប្រជាជាតិបានកំណត់និយមន័យឱ្យ ទេសចរណ៍ ថា "**ទេសចរណ៍** - ជាការធ្វើសកម្មភាពកម្សាន្ត ដែលជះឥទ្ធិពលទៅលើការពង្រឹងសុខភាព ការរីកចម្រើន និងអភិវឌ្ឍកម្លាំងកាយ និងកម្លាំងចិត្តរបស់មនុស្ស ដែលធ្វើចលនា ឬធ្វើដំណើរចេញពីកន្លែងរស់នៅជាប្រចាំក្នុងរយៈពេលណាមួយ"។

និយមន័យរបស់ទេសចរណ៍ ត្រូវបានកំណត់ទៅតាមលក្ខណៈពិសេសនៃសេដ្ឋកិច្ចនយោបាយ និងសង្គមរបស់វា។ នៅប្រទេសកម្ពុជា ក្រោយពីមានបំលាស់ប្តូរលើប្រព័ន្ធ

គ្រប់គ្រង និងឈានទៅប្រកាន់យករបបសេដ្ឋកិច្ចទីផ្សារសេរីនៅឆ្នាំ១៩៨៩ **ទេសចរណ៍** បានក្លាយទៅជាវិស័យឈានមុខមួយ នៅក្នុងវិស័យពាណិជ្ជកម្ម។ វាក្លាយទៅជាអាជីវកម្ម ដែលបោះជំហានទៅមុខយ៉ាងលឿន បើធៀបទៅនឹងវិស័យផ្សេងៗទៀតរបស់សេដ្ឋកិច្ចជាតិ។

ដូចបង្ហាញខាងលើៈ

- ការកំណត់និយមន័យទេសចរណ៍ ត្រូវធ្វើឡើងសំដៅទៅលើលក្ខណៈសេដ្ឋកិច្ចរបស់វា(សង្កត់ធ្ងន់ទៅលើអត្ថប្រយោជន៍វិស័យទេសចរណ៍ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ)
- និយមន័យរបស់ទេសចរណ៍ ត្រូវកំណត់ដោយផ្អែកលើឯកសារគោលរបស់អង្គការទេសចរណ៍ពិភពលោក ដែលតម្រូវប្រើប្រាស់សម្រាប់រៀបចំស្ថិតិទេសចរណ៍ពិភពលោក។ល។

នៅបណ្តាប្រទេសមួយចំនួន ក្នុងច្បាប់ជាតិ និងបទបញ្ញត្តិផ្សេងៗ ដែលជានីតិវិធីសារាចរ កម្មវិធី និយ័តកម្ម(Regulation) ដែលធ្វើឡើងសម្រាប់ការកំណែទម្រង់ទេសចរ-ណ៍ ការកំណត់ និយមន័យទេសចរណ៍ និងទេសចរ ត្រូវបានធ្វើឡើងដោយមានភាពខុសប្លែកពីគ្នា(មិនដូចគ្នាទាំងស្រុងទេ)ហើយការកំណត់ចំណាត់ថ្នាក់ និងវិភាគលើនិយមន័យនេះ ត្រូវបានទូទាត់ច្បាស់លាស់អំពីលទ្ធផលនយោបាយ និងបន្ទាប់មកសេដ្ឋកិច្ច។

ដោយខុសប្លែកពីការធ្វើដំណើរ **ទេសចរណ៍** - ជាការធ្វើដំណើរមួយដែរ របស់មហាជន ក្នុងរយៈពេលដ៏ខ្លីមួយតែមិនតិចជាង ២៤ ម៉ោង ហើយមិនលើសពីមួយឆ្នាំជាប់ៗគ្នា។ កត្តាទាំងនេះត្រូវបានគេធ្វើឡើងដោយផ្អែកលើទស្សនវិស័យពីរ ដូចខាងក្រោមៈ

- ទេសចរណ៍ចាំបាច់ស្ថិតនៅក្នុងប្រភេទអ្នកដែលបានមកដល់ ហើយមានការស្នាក់នៅយប់។ មានន័យថា ចាំបាច់ត្រូវរកទីកន្លែងសំណាក់។ មនុស្សមិនអាចឈរជើងបានក្នុងរយៈពេល ២៤ ម៉ោងនោះទេ គេចាំត្រូវសម្រាកដែលតម្រូវឱ្យជួល ឬទិញបន្ទប់សណ្ឋាគារ ផ្ទះសំណាក់ ឬមូលដ្ឋានសេវាកម្មស្នាក់នៅដទៃ។ល។
- ការធ្វើដំណើររយៈពេលយូរ ជានិច្ចជាកាលមានបុគ្គលតិចតួចតែប៉ុណ្ណោះ។ ការធ្វើដំណើរនេះ អាចពន្យាពេលដល់ទៅមួយ ឬច្រើនឆ្នាំសមស្របទៅតាមគោលបំណងនៃដំណើរ។ ជារៀងរាល់ឆ្នាំ មានការរៀបចំធ្វើដំណើរប្រភេទនេះ សម្រាប់គោលដៅផ្សេងៗ តែភាគច្រើនដើម្បីចងក្រងជាឯកសារ ការស្រាវជ្រាវវិទ្យាសាស្ត្រ។ល។ *ឧទាហរណ៍:* ដើម្បីអ្វីដែលចំណាយពេលជាច្រើនឆ្នាំក្នុងការធ្វើដំណើរតាមកង់ជុំវិញពិភពលោក ឬការធ្វើដំណើរផ្សងព្រេងតាមទូកជុំវិញមហា

សមុទ្រ។ល។ ការធ្វើដំណើរទាំងនេះ គ្មានទំនាក់ទំនងបន្តិចណាជាមួយទេសចរណ៍សោះទេ ព្រោះថាវាមានគោលដៅច្បាស់លាស់ ដែលមិនសមស្របនឹងគោលដៅរបស់ទេសចរណ៍ រីឯរយៈពេលធ្វើដំណើរក៏មានច្រើនលើសលុបពីការធ្វើដំណើរទេសចរណ៍ដែរ។

ការធ្វើដំណើរជាទេសចរណ៍ បានន័យថា ត្រូវទៅដល់ទីណាមួយក្នុងប្រទេស ឬនៅបរទេស ដែលមានសភាពប្លែកពីទីកន្លែង និងតំបន់ដែលទេសចររស់នៅ។ រីឯអ្នកដំណើរ(ទេសចរ) នេះត្រូវទស្សនាតំបន់នោះ ទៅតាមការកំណត់នៃខ្សែដំណើរទស្សនកិច្ចដែលខ្លួនបានទិញ ឯការទៅដល់ចាំបាច់ទាមទារពេលវេលាមួយរយៈមិនខ្លីមិនវែង ហើយត្រូវត្រឡប់មកទីកន្លែងរស់នៅស្រុកកំណើត ឬផ្ទះរបស់ខ្លួនវិញ។ បើសិនជាគេបន្តរស់នៅតំបន់ ដែលគេទៅដល់ក្នុងរយៈពេលវែង *ឧទាហរណ៍:* លើសពីមួយឆ្នាំ គេនឹងក្លាយទៅជាពលរដ្ឋនៃប្រទេសនោះជាបណ្ដោះអាសន្ន ឬក្លាយជាជនជាតិនៃប្រទេសនោះ ហើយទទួលបាននូវប័ណ្ណសម្គាល់ខ្លួន ឬប៉ាស្ព័រ(Passport)។ បន្ថែមលើនេះ គេអាចទាមទារការងារពីរដ្ឋអំណាច ឬចាំបាច់ត្រូវស្វែងរកការងារធ្វើដើម្បីចិញ្ចឹមជីវិត។ នេះជាបញ្ហាមួយរបស់អង្គការអន្តោប្រវេសន៍ និងអង្គភាពដទៃរបស់រដ្ឋាភិបាលប្រទេសនោះ ក្នុងការផ្ដល់នូវសិទ្ធិសេរីភាពរស់នៅ បំពេញការងារ ចូលសញ្ជាតិ និងស្នាក់នៅក្នុងប្រទេសនោះ។ អ្នកដំណើរប្រភេទនេះពុំត្រូវបានចាត់ទុកជា **ទេសចរ** (Tourist) នោះទេ។

ទេសចរណ៍ធ្វើឡើងនៅពេលទំនេរ (ក្រៅពីទេសចរណ៍អាជីវកម្ម - Business Tourism)។ ទាំងនេះអាចកើតមានឡើងដោយទាមទារចាំបាច់នូវលក្ខខណ្ឌពីរៈ ពេលទំនេរក្រៅពីការងារដែលផ្ដល់ដោយរដ្ឋាភិបាល ឬអង្គភាពបម្រើការងារសម្រាប់សម្រាក លំហែ និងមធ្យោបាយ(ពិសេសគឺប្រាក់ឧបត្ថម្ភ-ប្រាក់ Holiday ដែលផ្ដល់សម្រាប់ពេលទំនេរ ក្រៅពីការងារ ក្នុងរយៈពេលដែលកំណត់ដោយច្បាប់ពលកម្ម ក្នុងរយៈពេលមួយឆ្នាំម្ដង) សម្រាប់ប្រើប្រាស់ក្នុងរយៈពេលទំនេរនេះ ដើម្បីសម្រាកលំហែកាយ និងកម្សាន្តអារម្មណ៍ ។

តាំងពីនៅក្នុងសម័យ **អាណាចក្ររ៉ូម** ពលរដ្ឋដែលជាអ្នកមានជីវភាពខ្ពង់ខ្ពស់បានសម្រាក និងធ្វើដំណើរទៅកម្សាន្តនៅតំបន់ផ្សេងៗនៅជុំវិញ ពិសេស **អេហ្ស៊ីប** តាមរយៈដំណើរតាមទន្លេនីល ដែលជាប្រទេសសម្បូរទៅដោយសំណង់ធំៗ (ពីរ៉ាមីត)។ បច្ចុប្បន្ននេះ ថ្វីត្បិតប្រជាពលរដ្ឋទាំងអស់ក្នុងពិភពលោកពុំមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ធ្វើដំណើរជាទេសចរណ៍ក៏ពិតមែន តែបរិមាណអ្នកធ្វើដំណើរជាទេសចរណ៍ដែលមានកន្លងមក និងកំណើនរបស់វាជារៀងរាល់ឆ្នាំបានផ្ដល់នូវចំណាប់អារម្មណ៍យ៉ាងខ្លាំង ដល់ពលរដ្ឋនៃប្រទេសជាច្រើនក្នុងពិភពលោកទាំងមូល។

សរុបសេចក្តីមក **ទេសចរណ៍** ជាការធ្វើដំណើររបស់ពលរដ្ឋក្នុងរយៈពេលមួយ ពីតំបន់មួយ(ទីក្រុង ភូមិ ឃុំ ប្រទេស) ទៅតំបន់មួយ បើសិនជាវាមិនទាក់ទងទៅនឹង ការផ្លាស់ប្តូរទីកន្លែងរស់នៅ និងទីកន្លែងធ្វើការងារ។ **ទេសចរណ៍** ជាភាពសប្បាយរីករាយដែលបំពេញដល់មនុស្សនូវតម្រូវការដែលគេចង់បាន និងរង់ចាំក្នុងកំឡុងពេលដែលគេបំពេញការងារ តាមរយៈការធ្វើដំណើរក្នុងគោលបំណងសម្រាកលំហែកាយ អារម្មណ៍ ព្យាបាល ចូលរួមក្នុងពិធីបុណ្យ ការងារវិទ្យាសាស្ត្រ និងអាជីវកម្ម។

- នៅក្នុងច្បាប់ទេសចរណ៍របស់ **សាធារដ្ឋបារាំង** និយមន័យទេសចរណ៍ ត្រូវបានកំណត់ថា "ទេសចរណ៍ - ជាការធ្វើដំណើរក្នុងរយៈពេលមួយរបស់ពលរដ្ឋ ឬមហាជនពីទីស្នាក់នៅ(ផ្ទះ) របស់ខ្លួនទៅកាន់ប្រទេសណាមួយ ឬតំបន់ណាមួយក្នុងប្រទេស ក្នុងពេលទំនេរក្រៅពីការងារ ក្នុងគោលបំណងទទួលបានការសប្បាយរីករាយ សម្រាក ព្យាបាល ភ្ញៀវ ទស្សនកិច្ច ស្វែងយល់ សាសនា និងការងារអាជីវកម្ម តែមិនបានត្រូវអនុញ្ញាតឱ្យបំពេញការងារដែលទទួលបាននូវប្រាក់ ក្នុងតំបន់ដែលបានទៅដល់"។
- ច្បាប់ទេសចរណ៍របស់ **សហព័ន្ធរុស្ស៊ី** ទេសចរណ៍ - គឺជាការធ្វើដំណើរក្នុងរយៈពេលមួយរបស់ជនជាតិរុស្ស៊ី ជនជាតិបរទេស អ្នកដែលគ្មានសញ្ជាតិ ពីតំបន់ដែលខ្លួនរស់នៅ ក្នុងគោលបំណងព្យាបាល ថែរក្សាសុខភាព ទស្សនកិច្ច ស្វែងយល់ដឹង អាជីវកម្ម កីឡា សាសនា និងគោលបំណងផ្សេងៗ ក្រៅពីការស្វែងរកការងារដែលទទួលបានប្រាក់ក្នុងប្រទេស ឬតំបន់ដែលខ្លួនទៅដល់ក្នុងរយៈពេលធ្វើដំណើរនេះ។

និយមន័យទាំងពីរខាងលើនេះ មានភាពខុសគ្នាមែនតែអត្ថន័យរបស់វាប្រហាក់ប្រហែលនឹងគ្នា។ ក្រុមអ្នកច្បាប់នៃក្រសួងទេសចរណ៍ ដោយមានការដោះដូរយោបល់ពីអ្នកជំនាញពីមន្ត្រីរាជរដ្ឋាភិបាល បានសម្រេចផ្តល់និយមន័យឱ្យទេសចរណ៍សម្រាប់ព្រះរាជាណាចក្រ កម្ពុជាថា *"**ទេសចរណ៍** - ជាសកម្មភាពទាំងឡាយរបស់បុគ្គលដែលធ្វើដំណើរទៅ និងស្នាក់នៅកន្លែងផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេ សម្រាប់រយៈពេលដែលត្រូវកំណត់ ក្នុងគោលបំណងទេសចរណ៍ និងមិនទាក់ទងនឹងការផ្លាស់ប្តូរទីលំនៅ និងបម្រើការងារដើម្បីទទួលប្រាក់កម្រៃ"*។

ទេសចរណ៍ ពិតជាឧស្សាហកម្មធំសម្បើមរបស់ពិភពលោក បើសិនយើងពិនិត្យមើលចង្កោមធាតុរបស់វា។ ទេសចរណ៍ យោងតាមការវិភាគរបស់អង្គការទេសចរណ៍ពិភពលោក (United Nations World Tourism Organization – UNWTO) ជាវិស័យមួយរបស់

សេដ្ឋកិច្ចពិភពលោក។ វាបានដើរតួ (ចូលរួមចំណែក) យ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចពិភពលោក។




**រូបទី ២.២. ធាតុផ្សំសំខាន់របស់ទេសចរណ៍**




កត្តាចុងក្រោយនេះ បានផ្តល់ជាលទ្ធភាពដ៏ធំធេងសម្រាប់អ្នកដែលបានបញ្ចប់ការសិក្សា នៅវិទ្យាស្ថាន មហាវិទ្យាល័យ សាកលវិទ្យាល័យក្នុងជំនាញទេសចរណ៍។ ទេសចរណ៍ ជាវិស័យមួយរបស់សេដ្ឋកិច្ចដែលមានវ័យមធ្យម តែនៅក្មេងខ្ចីនៅឡើយក្នុងផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញ។ ការចេះគ្រប់គ្រងលើវិស័យទេសចរណ៍ ទាមទារចាំ

បាច់ដើម្បីឱ្យអាចកាត់បន្ថយការប៉ះពាល់ជាអវិជ្ជមានដល់សង្គមជាតិប្រទេសដែលទទួលភ្ញៀវ ដូចធ្លាប់មានជាប្រចាំនៅបណ្តាប្រទេសអឺរ៉ុបមួយចំនួន។

ជាទូទៅ ស្ថានភាពវិស័យទេសចរណ៍នៅបណ្តាប្រទេសអឺរ៉ុបដែលលើកខាងលើនេះមានៈ បរិមាណដ៏ច្រើនសន្ធឹកសន្ធាប់នៃទេសចរ លើសពីសមត្ថភាពដែលប្រទេសទាំងនោះមានសម្រាប់ការផ្គត់ផ្គង់ និងផ្តល់នូវការស្នាក់នៅ ការកម្សាន្ត ការបម្រើអារម្មណ៍ឱ្យបានល្អប្រសើរ។

## ២-២-មុខងារទេសចរណ៍

វិស័យទេសចរណ៍ តាមការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រក្នុងពិភពលោក កំពុងតែបំពេញនូវមុខងារសំខាន់បី (១)-មុខងារសេដ្ឋកិច្ច (២)-មុខងារសង្គមកិច្ច និង (៣)-មុខងារមនុស្សជាតិ។

**រូបទី ២.៣.មុខងាររបស់ទេសចរណ៍**




### ២-២-១-មុខងារសង្គមរបស់ទេសចរណ៍

- ផ្នែកមួយនៃការកម្សាន្តលំហែ ដែលជាជំនួយដល់ពលរដ្ឋក្នុងការរៀបចំ និងបង្កើនឡើងវិញនូវកម្លាំងពលកម្មរបស់ពួកគេ និងកាត់បន្ថយភាពធុញថប់។

- ជាសមិទ្ធិភាពមួយដែលនាំឱ្យមានការប្រើប្រាស់ឱ្យបានសុក្រឹត្យ (សមហេតុ សមផល) នូវពេលទំនេរ (Holiday) របស់ពលរដ្ឋក្រៅពីការងារ
- បង្កើតឱ្យមានការងារធ្វើ និងបង្កើនជីវភាពរស់នៅដល់ពលរដ្ឋតាមរយៈ (ក)- ការហូរចូលទឹកប្រាក់បរទេសមកក្នុងតំបន់ដែលវិស័យនេះរីកចម្រើន បង្កើនប្រាក់ចំណោញដល់អ្នកដែលផ្តល់សេវាកម្ម ជាហេតុធ្វើឱ្យអ្នកធ្វើសកម្មភាពទេសចរណ៍ទាំងអស់ បង្កើតនូវតម្លៃការងារដល់បុគ្គលិករបស់គេ និងទាមទារនូវកម្លាំងច្រើនដើម្បីផលិត និងផ្តល់សេវាផ្សេងៗ។ (ខ)-តំបន់ទេសចរណ៍ ត្រូវបានរៀបចំឱ្យមានការរីកដុះដាលនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មផ្សេងៗ ដូចជាគមនាគមន៍ ប្រៃសណីយ៍ ហាងទំនិញ មណ្ឌលកីឡា សណ្ឋាគារ ភោជនីយដ្ឋាន រមណីដ្ឋានកម្សាន្ត ដែលប្រជារាស្ត្រក្នុងតំបន់អាចប្រើប្រាស់បានដោយសេរី។
- នាំមកនូវការអភិវឌ្ឍន៍នៃសេដ្ឋកិច្ច និងសង្គមជាតិ កិច្ចការសហប្រតិបត្តិការរវាងប្រទេស និងប្រទេសក្នុងតំបន់ និងទ្វីប រវាងរដ្ឋ និងអាជីវករ និងក៏ដូចជាមួយប្រជាជន និងរវាងប្រជាជន និងប្រជាជន។ល។

## ២-២-២-មុខងារសេដ្ឋកិច្ចរបស់ទេសចរណ៍

ទេសចរណ៍ បានរួមចំណែកយ៉ាងសំខាន់ក្នុងការកសាង និងជំរុញឱ្យអភិវឌ្ឍសេដ្ឋកិច្ច ព្រោះវា៖

- ជាប្រភពដ៏សំខាន់មួយក្នុងការរកចំណូលដល់ពលរដ្ឋក្នុងតំបន់ទេសចរណ៍ តាមរយៈការបម្រើការងារដោយផ្ទាល់ ឬដោយប្រយោល ការលក់ដូរ និងសកម្មភាពផ្គត់ផ្គង់ផលិតផលជាទំនិញ និង,ឬសេវាកម្ម។
- ជាប្រភពនៃការធ្វើឱ្យសាខាផ្សេងៗនៃសេដ្ឋកិច្ចជាតិមានដំណើរការ តាមរយៈសកម្មភាពផលិតផ្ទាល់ ឬមិនផ្ទាល់នូវផលិតផលទេសចរណ៍ ឬផលិតផលដែលពាក់ព័ន្ធនឹងតម្រូវការទេសចរណ៍ សម្រាប់បំពេញតម្រូវការរបស់ទេសចរ។
- ជាកម្លាំងសម្រាប់ជំរុញការអភិឌ្ឍន៍អាជីវកម្មទីកន្លែងកម្សាន្ត រមណីយដ្ឋាន សួនកម្សាន្ត ឧទ្យាន ដែនជម្រកសត្វព្រៃ មណ្ឌលកីឡា មណ្ឌលពាណិជ្ជកម្ម និងទីកន្លែងកម្សាន្តសប្បាយដទៃដើម្បីទាក់ទាញឱ្យមានការមកកម្សាន្តក្នុងតំបន់ទេសចរណ៍។ល។
- ជាកម្លាំងសម្រាប់ជំរុញឱ្យមានការយកចិត្តទុកដាក់រៀបចំសម្ភារៈផ្សេងៗ សម្រាប់ទទួលភ្ញៀវ ការពារ និងថែរក្សាសម្បត្តិធម្មជាតិ វប្បធម៌ និងបេតិកភណ្ឌផ្សេងៗ សារមន្ទីរ ប្រាសាទ រូបបដិមា វិមាន ប្រវត្តិសាស្ត្រ។ល។

- ជំរុញឱ្យមានការរីកដុះដាលខ្លាំងនូវអាជីវកម្មដឹកជញ្ជូន ពង្រីកកន្លែងផ្តល់សេវាគមនាគមន៍ ដូចជា កន្លែងលាងនិងជួសជុលរថយន្ត ហាងសាំង គុណភាពផ្លូវថ្នល់។ល។ នៅក្នុងតំបន់ទេសចរណ៍និងតំបន់តភ្ជាប់ដែលមានតម្រូវការចាំបាច់។
- បង្កឱ្យមានការលក់បាន នូវទំនិញឧស្សាហកម្ម និងវត្ថុអនុស្សាវរីយ៍ជាច្រើន ដែលផលិតឡើងក្នុង និងក្រៅប្រទេស។ ការលក់ទំនិញទាំងអស់នេះក៏បានចូលរួមចំណែកក្នុងការផ្សព្វផ្សាយពីវិស័យទេសចរណ៍ផងដែរ។
- នាំឱ្យហូរចូលមកក្នុងតំបន់ និងប្រទេសអភិវឌ្ឍទេសចរណ៍រូបិយប័ណ្ណបរទេស នាំចំណូលដល់រដ្ឋអំណាចតំបន់ទេសចរណ៍ និងរដ្ឋាភិបាលប្រទេសតាមរយៈប្រាក់ពន្ធ ប្រាក់ទិដ្ឋការ និងចំណេញលើការលក់ទំនិញផ្សេងៗ។
- ជំរុញឱ្យមានការពង្រីកប្រព័ន្ធប្រាស្រ័យទាក់ទង( Telecommunication )ដើម្បីបង្កភាពងាយស្រួល ដល់ការធ្វើទំនាក់ទំនងក្នុង និងក្រៅប្រទេស (ប្រៃសណីយ៍ ទូរគមនាគមន៍ ទូរស័ព្ទគ្រប់ប្រភេទ ប្រព័ន្ធព័ត៌មានតាមរយៈកុំព្យូទ័រ )។ល។

### ២-២-៣-មុខងារមនុស្សជាតិរបស់ទេសចរណ៍

ក្រៅពីបានផ្តល់ជាប្រយោជន៍ដល់សេដ្ឋកិច្ច និងសង្គមកិច្ច ទេសចរណ៍បានបំពេញនូវតួនាទី ដ៏សំខាន់មួយទៀត គឺមនុស្សជាតិ ព្រោះថាវាបាននឹង៖

- ជំរុញឱ្យមានការចូលរួមពីសំណាក់មហាជន ក្នុងដំណើរកម្សាន្ត សម្រាក លំហែកាយ និងតាមរយៈការធ្វើដំណើរទស្សនា ស្វែងយល់ដឹង នាំឱ្យមហាជនបានស្គាល់អំពីជីវិត វប្បធម៌ ប្រវត្តិសាស្ត្រ ប្រពៃណី ទំនៀមទម្លាប់របស់ជាតិខ្លួន នឹងក៏ដូចជារបស់ជាតិ និងពលរដ្ឋដទៃទៀតដែរ។ កត្តាទាំងអស់នេះបានផ្តល់ដល់ពលរដ្ឋនូវការរីកចម្រើន ពង្រីកការយល់ដឹង និងបង្កើតឡើងនូវសតិសម្បជញ្ញៈស្នេហាជាតិ និងមាតុភូមិ។
- ជំរុញឱ្យមានការពង្រីក និងរៀបចំឡើងវិញនូវសន្តិសុខក្នុងសង្គមមនុស្ស មានទំនាក់ទំនងល្អ និងយោគយល់គ្នារវាងមនុស្សនិងមនុស្ស ពលរដ្ឋក្នុងប្រទេស និងតំបន់ ពលរដ្ឋប្រទេសមួយនិងពលរដ្ឋជនជាតិមួយផ្សេងទៀត។ ទំនាក់ទំនងល្អ និងកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសជិតខាងប្រទេសក្នុងតំបន់ និងប្រទេសក្នុងលោក ដែលជាលក្ខណៈមួយដ៏ល្អប្រសើរក្នុងការធ្វើបំលាស់ប្តូរអ្នកទេសចរ ការរកស៊ី និងជំនួញផ្នែកទេសចរណ៍ និងសេដ្ឋកិច្ចអន្តរជាតិ។
- បង្កើននូវការអប់រំ ដែលជាមូលដ្ឋានដល់កូនចៅជំនាន់ក្រោយ។ កម្មវិធីដំណើរល្អៗ អាចបង្កើនឱ្យមានអារម្មណ៍ល្អ ចិត្តគំនិតល្អដល់ក្មេង និងប្រសិទ្ធភាពក្នុងការ

រីកលូតលាស់ដល់ពួកគេនូវសិល្បវិធីល្អៗ ស្គាល់អំពីតម្លៃរបស់មនុស្ស និងសង្គម ។ល។

## ២-៣-ទេសចរជាកម្មបទរបស់ទេសចរណ៍

### ២-៣-១-អ្នកណាជាទេសចរ ? និយមន័យទេសចរ

នៅក្នុងវិស័យទេសចរណ៍ អ្នកដែលទទួលសេវាកម្មមានតែមួយគឺ **ទេសចរ**។ ទេសចរ ជាអ្នកទទួល និងប្រើប្រាស់នូវផលិតផលទេសចរណ៍។(កម្មវិធីដំណើរកម្សាន្ត ខ្សែទស្សនកិច្ច សេវាកម្ម ឬទំនិញ) និងត្រូវបានកំណត់ថាជាកម្មវត្ថុចម្បងនៃសកម្មភាពការងាររបស់ក្រុមហ៊ុន និងទីភ្នាក់ងារទេសចរណ៍។

ខុសគ្នាពីទីផ្សារទំនិញ និងផ្សារហិរញ្ញវត្ថុដែលផលិតផលជាអ្នកស្វែងរកអតិថិជន នៅក្នុងវិស័យទេសចរណ៍ អ្នកប្រើប្រាស់ផលិតផលនេះ (អតិថិជន ឬអ្នកទិញ) ស្វែងរកផលិតផលទេសចរណ៍ និងសេវាកម្មទេសចរណ៍ដោយខ្លួនឯង។ នេះជាលក្ខណៈពិសេសរបស់ទេសចរ ដែលជាអ្នកប្រើប្រាស់ផលិតផល និងសេវាកម្មទេសចរណ៍។ អ្នកប្រើប្រាស់ផលិតផល និងទទួលសេវាកម្មទេសចរណ៍គ្មានសិទ្ធិអាចសាកល្បង ឬស្គាល់ពីគុណភាពនៃសំណើមកគេនូវទស្សនកិច្ចកម្មវិធីដំណើរ សេវាកម្ម និងទំនិញជាមុនទេ។ ផលិតផលទេសចរណ៍ ត្រូវបានគេផ្តល់ ឬវាយតម្លៃក្នុងរយៈពេលនៃការប្រតិបត្តិ និងដំណើរការទទួលសេវានេះពីសំណាក់ទេសចរប៉ុណ្ណោះ។



Up top at Bakheng, this is what the tourists find. Cool, huh ?

ប្រសិទ្ធភាពនៃការអភិវឌ្ឍន៍វិស័យទេសចរណ៍ទាំងមូល ធ្វើឡើងតាមរយៈការធ្វើកិច្ចព្រមព្រៀងរវាងអាជីវករនិងអាជីវករ រវាងរដ្ឋនិងរដ្ឋ ហើយវាក៏មិនអាចកើតមានឡើងបើសិនជាគ្មានការកំណត់ច្បាស់លាស់ពីទេសចរណ៍នោះទេ។ កិច្ចព្រមព្រៀងជាលក្ខណៈអន្តរជាតិ រវាងរដ្ឋនិងរដ្ឋត្រូវបានធ្វើឡើងដោយយោងទៅតាមមិនត្រឹមតែគោលការណ៍គោលដៅ និងភារកិច្ចលើការដោះដូរទេសចរជាលក្ខណៈអន្តរជាតិប៉ុណ្ណោះទេ គឺបន្ថែមទាំងបន្ទូរបន្ថយពន្ធ និងបញ្ញាគយ ដែលអនុញ្ញាតឱ្យទេសចរក្នុងលក្ខខណ្ឌ នៃការឆ្លងកាត់ព្រំដែនប្រទេសមួយ លក្ខខណ្ឌធានារ៉ាប់រងទេសចរ បទបញ្ញត្តិ និងលក្ខខណ្ឌផ្សេងៗដែលតម្រូវក្នុងការអនុញ្ញាតឱ្យឆ្លងកាត់ព្រំប្រទល់ប្រទេស ឬទឹកដីដែលធ្វើដំណើរឆ្លងកាត់។

ការយល់ដឹងពីទេសចរណ៍ច្បាស់លាស់ នឹងបង្កជាលក្ខណៈដ៏ប្រសើរមួយសម្រាប់កិច្ចការសហប្រតិបត្តិការក្នុងទំនាក់ទំនងលើវិស័យទេសចរណ៍។ ហេតុនេះ យើងចាំបាច់ត្រូវកំណត់និយមន័យទេសចរឱ្យបានច្បាស់លាស់ជាមុន។

ពាក្យ**ទេសចរ** (Tourist) ត្រូវបានគេលើកយកមកកំណត់ និងផ្តល់និយមន័យជាច្រើនលើកមកហើយតែមកទល់សព្វថ្ងៃនេះ ពុំទាន់បានត្រូវបញ្ចប់ជាស្ថាពរនោះទេ ព្រោះសកម្មភាពទេសចរណ៍តែងតែវិវត្តស្របនិងការវិវត្តន៍នៃសង្គម និងចិត្តគំនិតរបស់ទេសចរ។ និយមន័យដំបូងរបស់ទេសចរ ត្រូវបានគេកំណត់នៅក្នុងសម័យប្រជុំរបស់អង្គការសហប្រជាជាតិ នៅក្នុងឆ្នាំ១៩៣៧ នាទីក្រុងហ្សឺណែវ ដែល *"**ទេសចរ** - ជាបុគ្គលដែលស្ថិតនៅមិនតិចជាង ២៤ ម៉ោង ក្នុងប្រទេសដែលគាត់មិនបានរស់នៅ"*។

និយមន័យនេះ មានន័យទូលំទូលាយពេកព្រោះថាវាអាចប្រើប្រាស់សម្រាប់គ្រប់ជនជាតិបរទេសដែលដែលស្ថិតនៅប្រទេសណាមួយលើសពី ២៤ ម៉ោង (អ្នកដំណើរឆ្លងកាត់ ជនភៀសខ្លួន ជនទុច្ចរិត អ្នកស៊ើបអង្កេត អ្នកដំណើរ។ល។) បញ្ហានេះបានជំរុញជាច្រើនលើកច្រើនសារ ដោយអង្គការសហប្រជាជាតិខិតខំលើកយកបញ្ហាកំណត់ន័យឱ្យទេសចរមកពិភាក្សាឡើងវិញ។

**ច្បាប់គយពិភពលោក** អនុម័តដោយអង្គការសហប្រជាជាតិ - United Nations (UN) នៅឆ្នាំ ១៩៥៤ នៅក្នុងមាត្រាទី១ មានការផ្តល់និយមន័យមួយថ្មីទៀតសម្រាប់ទេសចរ *"**ទេសចរ** - គឺបុគ្គលគ្រប់ប្រភេទ មិនប្រកាន់សាសនាដែលបានទៅដល់តំបន់ ឬទឹកដីប្រទេសណាមួយតាមរយៈកិច្ចព្រមព្រៀង(កិច្ចព្រមព្រៀងដោះដូរទេសចររវាងប្រទេស និងប្រទេស) ក្រៅពីប្រទេសដែលគេរស់នៅជាប្រចាំ ហើយស្ថិតនៅលើសពី ២៤ ម៉ោង និងមិនលើសពី ៦ ខែក្នុងគោលបំណងព្យាបាល កីឡា ទទួលភាពរីករាយ លំហែកាយ សិក្សា សាសនា អាជីវកម្ម និងកិច្ចការគ្រួសារដែលអាចធ្វើបាន ក្រៅពីការភៀស*

*ខ្លួន*"។

តាមរយៈនិយមន័យនេះ **ទេសចរ** គឺជាជនជាតិបរទេសដែលឆ្លងកាត់ព្រំប្រទល់ប្រទេសណាមួយ ដោយមិនមានគោលបំណងមករស់នៅជាប្រចាំ (ជនភៀសខ្លួន)។ និយមន័យនេះ មានលក្ខណៈទូលាយដែរ ព្រោះថាទេសចរអាចចាត់ទុកថាជាជនបរទេសដែលមកដល់ប្រទេសណាមួយ ដើម្បីរកការងារធ្វើ និងអាចធ្វើការងារពាក់ព័ន្ធនឹងបញ្ហានយោបាយ។

បញ្ហាដែលលើកឡើងនេះ បានជំរុញឱ្យអង្គសន្និសីទរបស់អង្គការសហប្រជាជាតិស្តីពី "ទេសចរណ៍ និងការធ្វើដំណើរ" ដែលប្រារព្ធឡើងនៅឆ្នាំ ១៩៦៣ កំណត់នូវនិយមន័យថ្មីមួយទៀតគឺ "***ទេសចរណ៍*** *- ជាអ្នកដែលមកដល់តំបន់ណាមួយ ក្នុងរយៈពេលមួយមិនតិចជាង ២៤ ម៉ោង រីឯគោលបំណងនៃការធ្វើដំណើរ គឺសម្រាកព្យាបាលខ្លួន សាសនា កីឡា ធ្វើអាជីវកម្ម ចូលរួមក្នុងសិក្ខាសាលា សិក្សា សន្និសីទ ការងារគ្រួសារ*"។ ឯអ្នកដែលធ្វើដំណើរទៅកាន់តំបន់ ឬប្រទេសណាមួយក្នុងគោលបំណងបំពេញការងាររដ្ឋជាផ្លូវការ (ទស្សនកិច្ចរបស់អ្នកដឹកនាំ ឬអង្គការណាមួយ សភាជាតិ សមាជិកស្ថានទូត ស្ថានកុងស៊ុល) ឬអ្នកដំណើរស្រាវជ្រាវវិទ្យាសាស្ត្រ (ភូមិវិទ្យា ប្រវត្តិវិទ្យា មហាសមុទ្រវិទ្យា ស្វែងរកកំណប់សត្វព្រៃ ស្វែងរកនិងកកាយកំណប់បូរាណវិជ្ជា។ល។) ពុំត្រូវបានបញ្ចូលក្នុងស្ថិតិរបស់ទេសចរទេ។ ចំពោះនិស្សិតដែលកំពុងសិក្សានៅបរទេស ត្រូវបានគិតថាជាទេសចរដែរ។

នៅក្នុងទ្រឹស្តីទេសចរណ៍ ដែលអាចប្រើប្រាស់បាន ពាក្យ **ទេសចរ** អាចត្រូវបានកំណត់ថាជាអ្នកប្រើប្រាស់ ឬទិញកម្មវិធីដំណើរកម្សាន្ត ផលិតផល និងសេវាកម្មទេសចរណ៍។ **ទេសចរ** - ជាបុគ្គលមិនប្រកាន់ជាតិ ភេទ សាសនា ភាសា ដែលមកដល់តំបន់ណាមួយក្នុងរយៈពេលណាមួយ ហើយស្នាក់នៅក្នុងតំបន់នោះ(ស្ថិតនៅក្រៅកន្លែងដែលខ្លួនរស់នៅជាប្រចាំ) ក្នុងសមាគមទីស្នាក់នៅណាមួយដោយខ្លួនឯង ឬជាក្រុម មិនតិចជាង ២៤ ម៉ោង តែមិនលើសពីមួយឆ្នាំ ក្នុងគោលបំណងស្វែងយល់ដឹង ទស្សនា ព្យាបាល អាជីវកម្ម និងមិនធ្វើសកម្មភាពណាដែលទាក់ទងនឹងនយោបាយ និងសេដ្ឋកិច្ចផ្ទាល់ខ្លួន ក្នុងតំបន់ដែលបានមកដល់។

ការកំណត់និយមន័យទេសចរ ច្បាស់លាស់អាចធ្វើទៅបានលុះត្រាតែ ពិនិត្យលើធាតុផ្សំរបស់វាដែលៈ

- ទេសចរ ជាអ្នកប្រើប្រាស់ផលិតផលទេសចរណ៍ (សេវាកម្ម ការងារ និងទំនិញ) ដែលត្រូវបានការពារដោយច្បាប់ "**ច្បាប់ការពារសិទ្ធិអតិថិជន**" ដែលមាននៅគ្រប់

ប្រទេសក្នុងពិភពលោក។ ទេសចរ កើតមានឡើងដោយសារតម្រូវការលើការសម្រាក លម្ហែ ធ្វើដំណើរ។ល។ និងបើគ្មានទេសចរ ក៏គ្មានទេសចរណ៍ដែរ។ សព្វថ្ងៃនេះមានអង្គការជាច្រើនដែលសិក្សា និងវាយតម្លៃលើការអនុវត្តច្បាប់ការពារសិទ្ធិរបស់អតិថិជន ព្រោះថា មានទេសចរជាច្រើនលាននាក់ក្នុងមួយឆ្នាំៗ មិនពេញចិត្តនឹងលក្ខខណ្ឌកម្សាន្តសម្រាក ធ្វើដំណើររបស់ខ្លួន និងបានប្ដឹងផ្ដល់ក្រោយពីបញ្ចប់ការធ្វើដំណើរជាទេសចរណ៍ ក្នុងករណីដែលការផ្ដល់សេវាមិនសមស្របនឹងកម្មវិធីដំណើរ ឬគុណភាពដែលអ្នកលក់បានសន្យា។

- ទេសចរ ជាអ្នកដែលបានស្នាក់នៅយប់ក្រៅពីកន្លែងរស់នៅរបស់ខ្លួន តែមិនលើសរយៈពេល ៣៦៥ ថ្ងៃ។ អ្នកមកដល់ហើយស្នាក់នៅលើសពី ៣៦៥ ថ្ងៃជាបន្តបន្ទាប់មិនត្រូវបានចាត់ទុក ថាជាទេសចរទេ។ តាមកត្តាផ្សេងៗរយៈពេលធ្វើដំណើរជាទេសចរណ៍ ត្រូវបានបែងចែកដូចខាងក្រោមៈ
  - ការធ្វើដំណើរនៅថ្ងៃទំនេរ Weekend Holiday ត្រូវស្ថិតក្នុងរយៈពេលពី១-៣ ថ្ងៃ។ ចរិកលក្ខណៈនៃដំណើរនេះបង្ហាញអំពីកម្រិតចំណាយតិចបំផុត លើការធ្វើដំណើរ ហើយពិសេសគឺសំដៅទៅតំបន់លំហែកាយ អារម្មណ៍ មជ្ឈមណ្ឌលវប្បធម៌ និងរមណីយដ្ឋានទេសចរណ៍។
  - ដំណើរក្នុងរយៈពេល ៥-៧ថ្ងៃ ត្រូវបានរីកដុះដាល និងទទួលបានការពេញនិយម យ៉ាងខ្លាំងនៅក្នុងពិភពលោក ទាំងសម្រាប់ទេសចរណ៍ដោយផ្ទាល់ និងទាំងសម្រាប់អ្នកប្រតិបត្តិការងារអាជីវកម្មទេសចរណ៍។
  - ដំណើរក្នុងរយៈពេល ៨-១២ថ្ងៃ សម្រាប់ប្រភេទណាមួយនៃទេសចរណ៍។ ដំណើរក្នុងរយៈពេលនេះ ត្រូវបានបន្ថយតម្លៃយ៉ាងច្រើន។ ចំណាយតិចសម្រាប់ការធ្វើដំណើរទៅតំបន់ដាច់ស្រយាលណាមួយ ក្នុងរយៈពេលពីរអាទិត្យជាងការធ្វើដំណើរពីរដង ដែលម្ដងមានរយៈពេលមួយសប្ដាហ៍។
  - ដំណើរក្នុងរយៈយូរអង្វែង - លើសពីពីរសប្ដាហ៍ (មិនលើសពី ៣៦៥ ថ្ងៃ)។ ការធ្វើដំណើររបៀបនេះ មានតិចនៅឡើយទេ ថ្វីត្បិតនៅក្នុងពិភពលោកមានការស្នើឡើងថា បើសិនជាបានទិញបន្ទប់សណ្ឋាគារសម្រាប់ស្នាក់នៅដល់ទៅពីរសប្ដាហ៍នោះ នៅសប្ដាហ៍ទីបីនេះ នឹងផ្ដល់បន្ទប់ដោយមិនគិតថ្លៃ។ ការធ្វើដំណើររបៀបនេះ ភាគច្រើនធ្វើឡើងទៅតាមប្រភេទទេសចរណ៍ពិសេសៗ ដូចជា Crossing Tour, Adventure Tour ជាដើម។
- ទេសចរត្រូវបានកំណត់ទៅតាមគោលបំណងនៃអ្នកដំណើរ និងវ័យរបស់គេ។ ព្រោះថាវ័យចំណាស់ជ្រុល អាចនាំឱ្យមានការលំបាកលើការថែរក្សា និងជួយដល់

សុខភាពពួកគាត់។ សម្រាប់ស្ថិតិទេសចរណ៍ និងប្រភេទអ្នកទេសចរត្រូវបានបែងចែកៈ កូនក្មេងគិតពី ៣-១២ ឆ្នាំ សិស្សគិតពី ១៤-១៨ ឆ្នាំ យុវវ័យ និងនិស្សិតគិតពី ១៨-២៥ឆ្នាំ និង មនុស្សពេញវ័យគិតពី ២៦-៤៤ ឆ្នាំ មនុស្សវ័យមធ្យមគិតពី ៤៥-៦៤ ឆ្នាំ និង ៦៥ ឆ្នាំ និងលើសមនុស្សចាស់ចូលនិវត្តន៍។

សម្រាប់ធ្វើគម្រោងផែនការរៀបចំផលិតផលទេសចរណ៍ វ័យមានលក្ខណៈសំខាន់ក្នុងការវាយតម្លៃ និងជ្រើសរើសសកម្មភាពទេសចរណ៍ និងប្រភេទផ្សេងៗរបស់វាឱ្យសមស្របទៅ នឹងការធ្វើដំណើរ។

ការកំណត់និយមន័យឱ្យទេសចរ ស្ថិតនៅលើគោលបំណងនៃការធ្វើដំណើរមួយទៀត។ បើសិនគោលបំណងនេះ មិនសមស្រប ទៅនឹងកត្តាដែលកំណត់នោះ អ្នកដំណើរមិនអាចត្រូវបានទទួលស្គាល់ថាជាទេសចរនោះទេ។ ក្នុងនោះ :

- ហាមធ្វើសកម្មភាពការងារសម្រាប់ផ្ទាល់ខ្លួននៅក្នុងតំបន់ដែលមកដល់ បើសិនអ្នកដំណើរនោះជាទេសចរ។ អ្នកទេសចរ ពុំត្រូវអនុញ្ញាតឱ្យប្រកបការងាររកប្រាក់ចំណូលនៅក្នុងតំបន់ដែលមកដល់ បើសិនជាអ្នកដំណើរនោះជាទេសចរ។ បើសិនជាកើតមានឡើងនូវបញ្ហានេះ គេពុំត្រូវបានចាត់ថាជាទេសចរជាដាច់ខាត។

មានន័យថា **ទេសចរ** ជាបុគ្គលដែលយកប្រាក់មកចាយវាយ និងបន្សល់វាទុក នៅក្នុងតំបន់ដែលខ្លួនមកដល់។ នេះជាច្បាប់សេដ្ឋកិច្ច ដែលតម្រូវឱ្យតំបន់ទេសចរណ៍ ត្រូវតែទទួលបានប្រាក់ចំណូល ពីការអភិវឌ្ឍន៍ទេសចរណ៍ ដែលជាវិស័យមួយដ៏សំខាន់របស់សេដ្ឋកិច្ចជាតិខ្លួន ព្រោះថាវាត្រូវផ្តល់ការងារដល់ពលរដ្ឋ ហូរចូលនូវទឹកប្រាក់បរទេសពីតំបន់ ឬប្រទេសផ្សេងៗ។

- ទេសចរក្នុងប្រទេស និងបរទេស និងបុគ្គលដែលមិនអាចចាត់ទុកជាប្រភេទទេសចរ។ តាមរយៈការបង្ហាញអំពីប្រភេទខាងលើនៃទេសចរណ៍ និងកត្តាផ្សេងៗរបស់វា យើងនឹងកំណត់អ្នកចូលរួមក្នុងសកម្មភាពទេសចរណ៍ក្នុងប្រទេស និងទេសចរណ៍អន្តរជាតិ (រូបទី ២.៤)។
- ទេសចរក្នុងប្រទេស ជាអ្នកដំណើរដែលក្នុងរយៈណាមួយបានស្នាក់នៅមួយយប់ ឬលើសក្នុងតំបន់ដែលបានមកដល់ក្នុងគោលបំណងទេសចរណ៍ក្នុងប្រទេស ឬក្នុងស្រុក និងខេត្តរបស់ខ្លួន ក្នុងរយៈពេលមិនលើសពីមួយឆ្នាំ ហើយមិនបានបំពេញការងាររកប្រាក់ចំណូលក្នុងតំបន់នេះ។ សម្រាប់ស្ថិតិទេសចរប្រភេទនេះ ត្រូវបានបញ្ចូលជនជាតិបរទេស ដែលរស់នៅជាប្រចាំក្នុងប្រទេសនេះ និងបានធ្វើដំណើរជាទេសចរណ៍ ឬស្នាក់នៅក្នុងតំបន់ទេសចរណ៍លើសពីមួយឆ្នាំ។ **អ្នក**

**ដែលពុំអាចចាត់ទុក ឬបញ្ចូលក្នុងស្ថិតិទេសចរក្នុងប្រទេសមានបង្ហាញតាម លំដាប់លំដោយដូចខាងក្រោម:**

- ប្រជាពលរដ្ឋក្នុងតំបន់ ដែលធ្វើដំណើរក្នុងប្រទេសរបស់ខ្លួនស្វែងរកទីលំនៅ
- បុគ្គលណាដែលធ្វើដំណើរក្នុងប្រទេសដើម្បីការងារ និងស្វែងរកប្រាក់ចំណូល
- បុគ្គលធ្វើដំណើរទៅតំបន់ផ្សេងៗក្នុងប្រទេសបំពេញការងារឱ្យអង្គភាពខ្លួន
- បុគ្គលធ្វើដំណើរពីតំបន់មួយទៅតំបន់មួយ ក្នុងគោលបំណងស្រាវជ្រាវ
- ពលទាហាន និងគ្រួសាររបស់គេចេញបម្រើកាតព្វកិច្ចក្នុងប្រទេស
- អ្នកដំណើរឆ្លងកាត់ (Transitor) ជនភៀសខ្លួន (Refugee)
- អ្នកដំណើរតាមនាវា រថយន្ត ឬរថភ្លើងធំៗ ដែលទទួលដំណោកក្នុងយានផ្ទាល់ខ្លួន
- អ្នកបើកបររថយន្ត យន្តហោះ នាវា ដែលប្រើប្រាស់សេវាកម្មស្នាក់នៅ

**រូបទី ២.៩.ការចាត់ថ្នាក់សម្រាប់ទេសចរណ៍ជាតិ និងអន្តរជាតិ**



- ទេសចរបរទេស (អន្តរជាតិ) ជាបុគ្គលដែលទទួលដំណោកក្នុងរយៈពេល ដែលបានស្នាក់នៅក្នុងតំបន់មកដល់មិនមែនជាប្រទេសរបស់ខ្លួន មិនលើសពីមួយឆ្នាំជាប់ៗគ្នា ហើយពុំបានធ្វើសកម្មភាពការងារសម្រាប់សេដ្ឋកិច្ចនិងជីវភាពផ្ទាល់ខ្លួន។

**ជនជាតិបរទេសដែលមកដល់ប្រទេសណាមួយ ហើយពុំត្រូវបានចាត់ទុកថាអ្នក ទេសចរ គឺ:**

- កម្មករបរទេស និងជនជាតិបរទេសដែលមកស្វែងរកការងារធ្វើ
- អ្នកមកសិក្សាក្នុងរយៈពេលលើសពី ៦ ខែ
- កម្លាំងទាហាន និងគ្រួសាររបស់គេដែលមកដល់ក្នុងទិសដៅមិនមែនទេសចរណ៍
- ស្ថានទូត និងតំណាងរបស់គេ និងគ្រួសារ អ្នកបម្រើការងារជាបុគ្គលិកក្នុងស្ថានទូត
- ជនភៀសខ្លួនជាជនជាតិបរទេសដែលមកដល់
- អ្នកដំណើរឆ្លងកាត់ (Transitor)
- អ្នកដំណើរតាមរថយន្ត រថភ្លើង នាវាសមុទ្រធំៗ ដែលទទួលដំណោកក្នុងយានយន្តរបស់គេ
- អ្នកបើកបរយានយន្ត ដូចបានរៀបរាប់ខាងលើ ហើយទទួលដំណោកក្នុងយានយន្តនេះ
- អ្នកបើកបរយន្តហោះដែលទទួលដំណោកនៅក្នុងសណ្ឋាគារប្រទេសដែលមកដល់។

ការកំណត់របៀបនេះ បានធ្វើឡើងឱ្យសមស្របទៅនឹងគោលការណ៍ដែលបោះពុម្ពផ្សាយ នៅឆ្នាំ១៩៧៨ ក្នុងឯកសារអង្គការសហប្រជាជាតិ UN – Provisional Guidelines on International Tourism (Statistical Papers. Series M. N2, United Nations Department of Economic and Social Affairs)។

សរុបសេចក្តីទៅ យើងអាចកំណត់ក្រុមផ្សេងៗរបស់ទេសចរដូចខាងក្រោម:

- ពលរដ្ឋដែលធ្វើដំណើរ សម្រាក លំហែកាយ អារម្មណ៍ ព្យាបាលជំងឺ ស្វែងយល់ដឹង។ល។
- ពលរដ្ឋដែលចេញទៅសិក្ខាសាលា ចូលរួមអង្គប្រជុំ សន្និសីទ វិទ្យាសាស្ត្រ កីឡា
- ពលរដ្ឋដែលធ្វើដំណើរទៅបំពេញភារកិច្ច និងកាតព្វកិច្ចជាទេសចរណ៍អាជីវកម្ម
- ពលរដ្ឋដែលធ្វើដំណើរទៅចូលរួមក្នុងព្រឹត្តិការណ៍សាសនា បុណ្យទាន។ល។

**ចំពោះអ្នកដែលពុំបានចាត់ទុកជាទេសចរ មាន៖**

- អ្នកដំណើរមកស្វែងរកការងារដោយផ្ទាល់ ឬតាមរយៈកិច្ចព្រមព្រៀងណាមួយ
- អ្នកដែលមកដល់ដើម្បីរស់នៅជាប្រចាំ
- បុគ្គលដែលទៅបំពេញការងារក្នុងតំបន់ផ្សេងៗក្នុងផ្ទៃប្រទេស ឬព្រំដែននៃប្រទេសផ្សេង។

ដូចបានកំណត់ខាងលើ នៅប្រទេសកម្ពុជាដើម្បីងាយស្រួលធ្វើរបាយការណ៍ ស្ថិតិទេសចរត្រូវបានឱ្យនិយមន័យថា *"**ទេសចរ** - ជាបុគ្គលដែលធ្វើដំណើរមកដល់តំបន់ទេសចរណ៍ ហើយស្នាក់នៅក្នុងរយៈពេលមួយ ចាប់ពី ២៤ ម៉ោងដល់មួយឆ្នាំ ក្នុងគោលបំណងព្យាបាល លំហែ ស្វែងយល់ ទស្សនា អាជីវកម្ម កីឡា សាសនា និងគោលដៅផ្សេងៗទៀត ក្រៅពីបំពេញការងារដើម្បីរកកម្រៃផ្ទាល់ខ្លួន និងស្វែងរកទីកន្លែងសម្រាប់រស់នៅ"*។

### ២-៣-២-សិទ្ធិរបស់ទេសចរ

ច្បាប់ទេសចរ បានបញ្ជាក់ពីសិទ្ធិ និងកាតព្វកិច្ចទេសចរបរទេសនៅក្នុងប្រទេសដែលគេបានទៅកម្សាន្តដោយសមស្របទៅនឹងនិយមន័យទេសចរ ដែលបានកំណត់ខាងលើ។ ក្នុងការរៀបចំខ្លួនសម្រាប់ធ្វើដំណើរកម្សាន្តជាទេសចរណ៍ និងក្នុងរយៈពេលកំពុងធ្វើដំណើរ រាប់បញ្ចូលទាំងការឆ្លងកាត់ **ទេសចរ** មានសិទ្ធិគ្រប់គ្រាន់ក្នុងការៈ

- ទទួលព័ត៌មានដែលចាំបាច់ សម្រាប់ធ្វើដំណើរទៅប្រទេសជាគោលដៅក្នុងរយៈពេលណាមួយ អំពីទំនៀមទម្លាប់របស់មហាជនតំបន់នោះ ការប្រាព្ធបុណ្យសាសនា សម្បត្តិធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី និងមជ្ឈមណ្ឌលរមណីយដ្ឋានទេសចរណ៍ដទៃទៀត ដែលស្ថិតនៅក្រោមការការពារ និងថែរក្សាស្ថានភាពបរិស្ថានក្នុងតំបន់។
- មានសិទ្ធិគ្រប់គ្រាន់ក្នុងការធ្វើចលនាជាសេរី មានលទ្ធភាពចូលទៅតំបន់ដែលមានធនធានទេសចរណ៍សមស្របទៅនឹងការកំណត់របស់ប្រទេសដែលបានទៅដល់ នៅក្នុងរយៈពេលដែលបានស្នាក់នៅ និងធ្វើសកម្មភាពទេសចរណ៍។
- ត្រូវបានផ្តល់សន្តិសុខគ្រប់គ្រាន់សម្រាប់ខ្លួនផ្ទាល់ និងសម្ភាររបស់ខ្លួន ព្រមទាំងមានសិទ្ធិគ្រប់គ្រាន់សម្រាប់ទទួលជំនួយសេវាសុខភាព សេវាកម្មសង្គ្រោះបន្ទាន់ និងសេវាកម្មសាធារណៈដទៃបើសិនជាចាំបាច់។

- ទទួលបាននូវប្រាក់ជំងឺចិត្ត ឬសម្ភាង បើសិនជាគ្មានការផ្តល់សេវាតាមលក្ខខណ្ឌនៃកិច្ចសន្យា ធ្វើដំណើរកម្សាន្តតាមច្បាប់ប្រទេសទៅដល់ ពីក្រុមហ៊ុនដែលលក់ និងផ្តល់សេវាដល់ខ្លួន។
- ទទួលពីរដ្ឋអំណាចតំបន់ក្នុងប្រទេស ឬតំបន់ដែលទៅដល់ ជំនួយតាមផ្លូវច្បាប់បើសិនជាមានឧបសគ្គ និងត្រូវបានផ្តល់លទ្ធភាពគ្រប់គ្រាន់សម្រាប់ធ្វើទំនាក់ទំនងតាមរយៈប្រៃសណីយ៍។

**២-៣-៣-ភារកិច្ចទេសចរ**

ក្នុងរយៈពេលធ្វើដំណើរ (ដោយរាប់បញ្ចូលទាំងដំណើរឆ្លងកាត់) **ទេសចរ** ចាំបាច់ត្រូវៈ

- គោរពច្បាប់ប្រទេស និងតំបន់ទេសចរណ៍ដែលខ្លួនទៅដល់
- គោរពសង្គមជាតិ សាសនា ប្រពៃណី ទំនៀមទម្លាប់ វប្បធម៌តំបន់ទេសចរណ៍
- ចូលរួមចំណែកថែរក្សាបរិស្ថាន យកចិត្តទុកដាក់លើសម្បត្តិវប្បធម៌ បេតិកភណ្ឌប្រវត្តិសាស្ត្រ
- គោរពច្បាប់អន្តោប្រវេសន៍ និងការឆ្លងកាត់ព្រំប្រទល់ប្រទេសដែលខ្លួនឆ្លងកាត់
- គោរពគោលការណ៍សន្តិសុខ និងអនាម័យក្នុងការធ្វើដំណើរ
- ជៀសវាងការប្រព្រឹត្តល្មើស ធ្វើឱ្យខូចខាតដល់ប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌
- ជៀសវាងការធ្វើឱ្យខូចខាតដល់សណ្តាប់ធ្នាប់សង្គម សុខភាពទូទៅរបស់ប្រជាពលរដ្ឋ
- ហាមធ្វើអាជីវកម្មភេទ រត់ពន្ធ និងធ្វើអាជីវកម្មថ្នាំញៀន លាងលុយកខ្វក់
- ហាមធ្វើសកម្មភាពពាក់ព័ន្ធនឹងនយោបាយ វិច្ឆេទកម្ម បង្កអសន្តិសុខក្នុងតំបន់ទេសចរណ៍

ទេសចរ អាចត្រូវបានពិន័យជាទឹកប្រាក់ ហាមឃាត់មិនឱ្យទៅកាន់តំបន់ ឬរមណីយដ្ឋាន លប់ចោលទិដ្ឋការ ទទួលទណ្ឌកម្ម ឬបណ្តេញពីតំបន់ទេសចរណ៍ ប្រសិនបើប្រព្រឹត្តល្មើសការកំណត់នេះ។



Child Sex Tourism

ជាអ្នកប្រើប្រាស់ផលិតផល និងសេវាកម្មទេសចរណ៍ **ទេសចរ** ត្រូវបានបែងចែកជាច្រើនប្រភេទផ្សេងៗគ្នាទៅតាមចរិកលក្ខណៈរបស់ពួកគេ៖

- ទេសចរ ដែលសន្សំសំចៃ (អ្នកទិញផលិតផលទេសចរណ៍ ដែលសន្សំសំចៃ) ជាអ្នកទិញដែលនិយមចូលចិត្តផលិតផលដែលមានគុណភាពសមស្រប និងមានតម្លៃលក់ថោកស្របតាមលទ្ធភាពទិញ និងចំណាយរបស់ពួកគេ។
- ទេសចរ ព្រងើយកន្តើយ (អ្នកទិញផលិតផលទេសចរណ៍ មានចរិតព្រងើយកន្តើយ) អ្នកទិញប្រភេទនេះយកចិត្តទុកដាក់ជាពិសេសទៅលើគុណភាពសេវាកម្មទេសចរណ៍ រីឯតម្លៃផលិតផលមិនជាសំខាន់នោះទេ។
- ទេសចរ មានចរិយាមាយាទខ្ពស់ (អ្នកទិញផលិតផលដែលមានចរិយាមាយាទខ្ពស់) គេចង់បានផលិតផលមានតម្លៃសមរម្យ តែមានសេវាកម្មប្លែកៗ និងពិសេស។
- ទេសចរពិសេស (អ្នកទិញផលិតផលទេសចរណ៍ពិសេសៗ) គេចង់បានប្រភេទណាមួយនៃផលិតផលទេសចរណ៍ មានគុណភាពខ្ពស់ រីឯតម្លៃនៃផលិតផលមិនជាការសំខាន់នោះទេ។

ដើម្បីសមស្របទៅតាមប្រភេទផ្សេងៗនៃតម្រូវការលើផលិតផលទេសចរណ៍ **ទេសចរ** ត្រូវបានបែងចែកជាបីប្រភេទផ្សេងៗគ្នា។ ក្នុងនោះ៖

- ពលរដ្ឋ ដែលមានតម្រូវការលើទេសចរណ៍ប្រភេទដំណើរកម្សាន្ត និងលំហែកាយ អារម្មណ៍។ ពួកគេចាប់អារម្មណ៍ទៅលើផលិតផលមានលក្ខណៈទាក់ទាញពិសេស។
- ពលរដ្ឋ ដែលមានតម្រូវការលើផលិតផលទេសចរណ៍ ប្រភេទដែលជាសេវាកម្ម មានកម្រិតគុណភាពខ្ពស់ និងលក្ខណៈពិសេសៗផ្សេងៗទៀត។
- ពលរដ្ឋ ដែលជាអ្នកទិញធម្មតា (សកម្មភាពទិញភាគច្រើន បានមកពីការផ្សាយពាណិជ្ជកម្មដែលអាចទាក់ទាញអារម្មណ៍របស់ពួកគេ)។

## ២-៤-គោលបំណងទេសចរ និងអ្នករៀបចំចាត់ចែងការងារទេសចរណ៍

មានចំណុចមួយដែលបម្រើឱ្យអារម្មណ៍ គឺបំណងប្រាថ្នា (ធ្វើ ដឹង ឃើញ កម្សាន្ត ។ល។) បានបង្ខំឱ្យមនុស្សក្នុងរយៈពេលដ៏វែងបានសន្សំទឹកប្រាក់របស់ខ្លួន ដើម្បីក្នុងរយៈពេលដ៏ខ្លីណាមួយធ្វើដំណើរចេញពីផ្ទះរបស់ខ្លួនទៅតំបន់ណាមួយ ដើម្បីសម្រាក លំហែកាយ អារម្មណ៍ ស្វែងរកភាពសប្បាយរីករាយ ធ្វើបំលាស់ប្តូរបរិយាកាសដែលប៉ងជាយូរ។

យើងធ្វើការសិក្សាទៅលើបំណងប្រាថ្នា ដែលទេសចរបរទេសចង់បានពីទេសចរណ៍ (Travelers Expectation of Foreign Destination)។ អ្នកវិទ្យាសាស្ត្រឆ្លងតាមការស្រាវជ្រាវរបស់ខ្លួន បានបង្ហាញពីបំណងប្រាថ្នាទៅលើទេសចរណ៍ ដូចមានបង្ហាញខាងក្រោមៈ

- សិក្សា និងបានស្គាល់អំពីវប្បធម៌ប្លែកៗថ្មីៗ ទំនៀមទម្លាប់ ប្រពៃណី ចំណីអាហារ
- បានស្គាល់ និងកម្សាន្តជាមួយជីវិតប្លែកៗ ដូចជាជីវិតក្នុងពេលរាត្រី
- លទ្ធភាពទៅកម្សាន្តលម្ហែ នៅភោជនីយដ្ឋាន រមណីយដ្ឋានលម្ហែ។ល។
- មានលទ្ធភាពចូលរួមរស់នៅមួយរយៈក្នុងជីវិតថ្មីមួយ ដែលគ្មានសម្រាប់ខ្លួនពីមុន
- ទិញទំនិញ វត្ថុអនុស្សាវរីយ៍ ចំណាយប្រាក់ទំនេររបស់ខ្លួនដែលសន្សំអស់រយៈពេលយ៉ាងយូរ
- ទទួលនូវអារម្មណ៍ជាមនុស្សផ្សេង មនុស្សកម្រិតខ្ពស់
- បំលាស់ប្តូរបរិយាកាស បន្ធូរបន្ថយអារម្មណ៍ សម្រាកលម្ហែ
- ទស្សនាល្ខោន មហោស្រព តន្ត្រី ការប្រឡងប្រជែង
- ជួបជាមួយមនុស្សថ្មីដែលជាទីគាប់ចិត្ត
- ស្វែងយល់ និងសិក្សាពីលក្ខន្តិកៈសម្រាប់ធ្វើអាជីវកម្មក្នុងប្រទេស ឬតំបន់ណាមួយ
- គោលបំណងទិញទំនិញសម្រាប់ធ្វើបំលាស់ប្តូរ និងធ្វើពាណិជ្ជកម្ម
- ទិញវត្ថុអនុស្សាវរីយ៍ ជំនួន និងសម្រាកនៅមាត់សមុទ្រ ល្បែង កីឡា

- ព្យាបាល កែលម្អសុខភាពផ្ទាល់ខ្លួនឡើងវិញ
- សាសនា និងដំណើរស្វែងយល់ពីសាសនា តំបន់សាសនានៃអ្នកប្រកាន់សាសនា
- ជួបនឹងបងប្អូន ញាតិមិត្ត មិត្តភក្តិ

ទេសចរ ជានិច្ចកាលប្រើប្រាស់សេវាកម្មក្រុមហ៊ុន ឬទីភ្នាក់ងារណាមួយ។ បើសិនជាការធ្វើដំណើរលើកដំបូងពួកគេពេញចិត្ត និងទទួលបាននូវអ្វីដែលជាបំណងប្រាថ្នារបស់គេ កម្រិតសេវាកម្មដែលបម្រើមានកម្រិត និងគុណភាពខ្ពស់ល្អសមរម្យ ស្របនឹងទំហំទឹកប្រាក់ដែលគេចំណាយ គេនឹងត្រឡប់មកទទួលសេវានៅក្រុមហ៊ុននេះម្តងទៀត (នៅពេលសម្រេចចិត្តធ្វើដំណើរជាថ្មីម្តងទៀត) និងក្នុងករណីដែលក្រុមហ៊ុនអាចផ្តល់ និងបម្រើគេនូវអ្វីដែលគេចង់បានផ្សេងៗទៀត។ ហេតុនេះហើយ បានជាក្រុមហ៊ុនធំៗ ជារៀងរាល់ឆ្នាំតែងតែបង្កើតផលិតផលទេសចរណ៍ ឬខ្សែទស្សនកិច្ចថ្មីៗ។

អ្នកស្រាវជ្រាវវិទ្យាសាស្ត្រទេសចរណ៍ ជនជាតិ **អាល្លឺម៉ង់** ដែលសិក្សាអំពីតម្រូវការលើផលិផលទេសចរណ៍ ក្នុងរយៈពេលដែលទេសចរបានធ្វើទំនាក់ទំនងជាមួយក្រុមហ៊ុនរបស់គាត់ បានសន្និដ្ឋានថាសម្រាប់ពួកទាំងនេះ អ្វីដែលសំខាន់គឺៈ

- មានជំនាញអាចផ្តល់យោបល់ល្អៗថាតើគួរធ្វើដំណើរកម្សាន្ត ឬសម្រាកយ៉ាងដូចម្តេច? ៦៨%
- ទីស្នាក់ការ ឬការិយាល័យរបស់ទីភ្នាក់ងារទេសចរណ៍ ៥១%
- បរិយាកាសរបស់ទីស្នាក់ការ ឬការិយាល័យរបស់ទីភ្នាក់ងារទេសចរណ៍ ៥១%
- សេវាមានគុណភាពខ្ពស់ ៤៦%
- តម្លៃសមរម្យ ៤២%
- មានផលិតផលច្រើនប្រភេទដែលអាចជ្រើសរើសតាមចិត្ត ៤២%

ប៉ុន្តែគ្រប់ទេសចរជានិច្ចកាល លើកដំបូងបានយកចិត្តទុកដាក់ខ្លាំងលើកម្រិតទុកចិត្ត (ភាពអាចជឿជាក់ និងទុកចិត្តបាន) របស់គេទៅលើក្រុមហ៊ុន *"តើទុកចិត្តបានឬទេក្រុមហ៊ុននេះ មិនបោកប្រាស់ភូតកុហកទេ ឬយ៉ាងណា?"* (មិត្តទាំងឡាយត្រូវចង់ចាំឱ្យច្បាស់ថា មនុស្សខ្លាច និងមិនចង់ទទួលនូវសេវាកម្មមិនល្អ មិនចង់បាន និងទទួលអ្វីដែលគេពុំចង់បាននោះទេ)។

សមាគមស្ថិតិទេសចរណ៍ពិភពលោក បានកំណត់គោលបំណងរបស់ទេសចរ ដូចខាងក្រោម:

- ធ្វើសកម្មភាពទេសចរណ៍ សម្រាកលម្ហែ - ទស្សនាប្រាសាទបុរាណ កីឡា សមុទ្រ ល្បែង
- រីករាយ និងសម្រាក - ពង្រឹងសុខភាព និងទឹកចិត្ត កីឡាដើម្បីកម្លាំងកាយ និងបន្ធូរអារម្មណ៍
- ព្យាបាល និងថែរក្សាសុខភាព - ដំណើរក្នុងគោលបំណងព្យាបាល ពិនិត្យសុខភាព
- ការងារទំនាក់ទំនងនឹងអាជីវកម្ម - ចូលរួមក្នុងពិព័រណ៍ សន្និសីទ ការងារអាជីវកម្ម
- គោលដៅផ្សេងៗ - សកម្មភាពអ្នកបើកបរដឹកអ្នកដំណើរ (យន្តហោះ នាវា រថយន្ត)
- ទេសចរណ៍ ក្នុងគោលបំណងប្រឆាំងនឹងសីលធម៌ និងចរិយាសាស្រ្ត - ទេសចរណ៍ភេទ
- សាកសួរសុខទុក្ខញាតិសន្តាន បងប្អូន ឬមិត្តភក្តិ
- ធ្វើដំណើរជាមួយគោលបំណងសាសនា និងចូលរួមក្នុងព្រឹត្តការណ៍បុណ្យទានធំៗ។